**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

លេខ ៣៩៥ ស.អ.យ.

*រាជធានីភ្នំពេញ,ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០៥*

# ប្រកាស

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្រុក ខណ្ឌ

## រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

-បានឃើញប្រកាសលេខ ៣៥៩ សអយ ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០៥ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត ក្រុង

-ពិនិត្យឃើញការចាំបាច់របស់ក្រសួង

## ស ម្រេ ច

**ប្រការ១.-** ប្រកាសនេះ កំណត់ការអនុវត្តតួនាទីភារកិច្ច រចនាសម្ព័ន្ធ និងការបែងចែកភារកិច្ច របស់ការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្រុក ខ័ណ្ឌ ដែលមានចែងនៅក្នុងប្រកាសលេខ ៣៥៩ សអយ ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មន្ទីរ សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត ក្រុង ។

**ប្រការ២.-** ការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្រុក ខ័ណ្ឌ មានភារកិច្ចអនុវត្ត និងសម្របសម្រួលសកម្មភាពការងារ របស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត ក្រុង នៅក្នុងស្រុក ខ័ណ្ឌ ។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ, ទូរស័ព្ទ/ទូរសារ : (៨៥៥) ២៣ ៧២៦០៨៦
Ministry of Social Affairs, Veterans and Youth Rehabilitation, #788, Monivong Blvd., Phnom Penh, Cambobodia. Fax/Phone: (855) 23 726086

**ប្រការ៣.-** រចនាសម្ព័ន្ធ និងអង្គការលេខ :

ការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្រុក ខណ្ឌ ដឹកនាំដោយប្រធានមួយរូប ដែលមានឋានៈស្មើអនុប្រធានការិយាល័យនៃមន្ទីរខេត្ត ក្រុង និងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

រចនាសម្ព័ន្ធ អង្គការលេខ របស់ការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាស្រុក ខណ្ឌ ត្រូវចែកចេញជា ៣ ផ្នែក :

**ក-ផ្នែក រដ្ឋបាល**

**ខ-ផ្នែក សង្គមកិច្ច និងយុវនីតិសម្បទា**

**គ-ផ្នែក អតីតយុទ្ធជន**

ភារកិច្ច របស់ផ្នែកនីមួយៗ មានដូចខាងក្រោម :

**ក-ផ្នែករដ្ឋបាល** :

-ទទួលខុសត្រូវការងាររដ្ឋបាលរបស់ការិយាល័យ រួមមាន :

-លិខិតចេញ ចូល

-របៀបរបប សន្តិសុខ សណ្តាប់ធ្នាប់ បទបញ្ជាផ្ទៃក្នុង

-គ្រប់គ្រងទ្រព្យសម្បត្តិ ចលនទ្រព្យ អចលនទ្រព្យ

-បើកប្រាក់បៀវត្សរ៍ ជូនមន្ត្រីរាជការ

-សម្របសម្រួលកិច្ចការផ្សេងៗរបស់ការិយាល័យ ។

**ខ-ផ្នែកសង្គមកិច្ច និង យុវនីតិសម្បទា**

-ប្រមូលពត៌មានស្តីពីស្ថានភាពប្រជាជនដែលងាយទទួលរងគ្រោះក្នុងស្រុក ខណ្ឌ រួមមាន ជនអនាថា យុវកុមារ ដែលប្រព្រឹត្តអំពើអបាយមុខ ជនចាស់ជរាគ្មានទីពឹង កុមារកំព្រាកុមារត្រូវគេបោះបង់ចោល ស្រីពេស្យា ប្រជាជនរងគ្រោះដោយធម្មជាតិ អគ្គីភ័យ ខ្យល់ព្យុះ ទឹកជំនន់ ។ល។

-គ្រប់គ្រងបញ្ជីបើកប្រាក់ និងបើកប្រាក់ឧបត្ថម្ភគោលនយោបាយជូននិវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ តាមការប្រគល់ភារកិច្ចរបស់មន្ទីរ

-ធ្វើការតាមដានស្ថានភាព ជីវភាពរបស់និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ និងគ្រួសារ

-អនុវត្តកម្មវិធីសមាហរណកម្មជនអនាថារបស់មន្ទីរ ។

**គ-ផ្នែកអតីតយុទ្ធជន**

-គ្រប់គ្រងស្ថិតិជនពិការគ្រប់ប្រភេទ គ្រប់វ័យ ដែលស្ថិតនៅក្នុងស្រុក ខណ្ឌ

-គ្រប់គ្រងស្ថិតិជនពិការដែលបានបណ្តុះបណ្តាលរួចហើយ និង មិនទាន់បានបណ្តុះបណ្តាល

-គ្រប់គ្រងស្ថិតិជនពិការដែលបានទទួល និង មិនទាន់បានទទួលសេវាស្តារលំរាងកាយ

-គ្រប់គ្រងបញ្ជីបើកប្រាក់ និងបើកប្រាក់ឧបត្ថម្ភរបបគោលនយោបាយ ជូនមុខសញ្ញាអតីតយុទ្ធជន និងគ្រួសារ ដែលត្រូវទទួលរបបគោលនយោបាយរបស់រដ្ឋ តាមការប្រគល់ភារកិច្ចរបស់មន្ទីរ

**ប្រការ៤.-** ការបែងចែកភារកិច្ច :

ក្នុងករណីការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាស្រុក ខ័ណ្ឌ ដែលមានប្រធាន និងអនុប្រធាន ការបែងចែកភារកិច្ច ត្រូវអនុវត្តដូចខាងក្រោម :

-ប្រធានការិយាល័យ ទទួលរួម និងទទួលបន្ទុកផ្នែករដ្ឋបាល ផ្នែកសង្គមកិច្ច និងយុវនីតិសម្បទា ឬ ផ្នែកអតីតយុទ្ធជន

-អនុប្រធានការិយាល័យ ទទួលបន្ទុក ផ្នែកជំនាញណាមួយ ។

**ប្រការ៥.-** ការរៀបចំពង្រាយមន្ត្រីរាជការឱ្យបំពេញការងារនៅការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាស្រុក ខ័ណ្ឌ :

មន្ទីរ ត្រូវពិនិត្យ រៀបចំឱ្យអស់លទ្ធភាព នូវមន្ត្រីរាជការរបស់មន្ទីរ ដើម្បីពង្រាយមន្ត្រីឱ្យទៅបំរើការងារនៅការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាស្រុក ខ័ណ្ឌ ឱ្យបានពី ០១នាក់ ទៅ ០៣ នាក់ ក្នុងមួយស្រុក ខ័ណ្ឌ នីមួយៗ ។

ក្រសួង លើកទឹកចិត្តឱ្យមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត ក្រុង ទទួលយកមន្ត្រីក្របខ័ណ្ឌនៅតាមក្រសួង ស្ថាប័ន អង្គភាពនានា ដែលមានបំណងផ្ទេរក្របខ័ណ្ឌមកបំរើការនៅការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាស្រុក ខ័ណ្ឌ ។

ក្នុងករណីមានការងារច្រើនចាំបាច់ ហើយខ្វះខាតមន្ត្រីសំរាប់បំរើការងារនៅការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាស្រុក ខ័ណ្ឌ ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត ក្រុង ត្រូវលើកសំណើជូនក្រសួងសុំប្រើប្រាស់នូវមន្ត្រីជាប់កិច្ចសន្យា ។

**ប្រការ៦.-** ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

**អ៊ិត សំហេង**

**ចម្លងជូន:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **កៀ ចាញ់**
-ក្រសួងមហាផ្ទៃ
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
-គ្រប់សាលាខេត្ត ក្រុង
" ដើម្បីជូនជ្រាប "
-គ្រប់អង្គភាពក្រោមឱវាទក្រសួង " ដើម្បីអនុវត្ត "
-ឯកសារ -កាលប្បវត្តិ